**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

---

# កិច្ចប្រជុំ

**រវាង**

**តំណាងរោងចក្រ ជេ អេ ដាប់ប៊ែលយូ ឯ.ក**

**និង**

**សហជីពមូលដ្ឋាន និងប្រតិភូបុគ្គលិក**

**ស្តីអំពីការព្យួរកិច្ចសន្យាការងារ**

នៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២៣ វេលាម៉ោង ៩ និង៣០នាទី នៅក្នុងរោងចក្រ ជេ អេ ដាប់ប៊ែលយូ ឯ.ក មានទីតាំងផ្លូវលំ ភូមិជំរៅ សង្កាត់គោករកា ខណ្ឌព្រែកព្នៅ មានកិច្ចប្រជុំមួយរវាងតំណាងក្រុមហ៊ុន សហជីពមូលដ្ឋាន និងប្រតិភូបុគ្គលិក ស្តីអំពីការព្យួរកិច្ចសន្យាការងារ ។

នៅក្នុងអង្គប្រជុំនេះ តំណាងក្រុមហ៊ុនបានជូនដំណឹងដល់កម្មករនិយោជិតទាំងអស់អំពីស្ថានភាពបច្ចុប្បន្ននៅក្នុងរោងចក្រថា ដោយសារវិបត្តិសេដ្ឋកិច្ចជាសកល ក្រុមហ៊ុនយើងខ្វះខាតសម្ភារវត្ថុធាតុដើមសម្រាប់ផលិត (ពុំមានការបញ្ជាទិញ) ដែលមិនអាចអោយចង្វាក់ផលិតកម្មរបស់រោងចក្រដំណើរការបាន ហេតុដូចនេះ ក្រុមហ៊ុនសម្រេចធ្វើការព្យួរកិច្ចសន្យាការងារកម្មករ និយោជិតចំនួន ៦៤២នាក់ ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន ៦៤២នាក់ រយៈពេលចំនួន ២៨ថ្ងៃ គឺចាប់ពីថ្ងៃទី១៨ ខែ កក្កដា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី១៤ ខែសីហា ឆ្នាំ ២០២៣ហើយនៅក្នុងអំឡុងពេលនៃការព្យួរកិច្ចការងារនេះកម្មករនិយោជិត បាន·ឯកភាពទទួលយកប្រាក់ឧបត្ថម្ភដែលក្រុមហ៊ុនផ្តល់ជូនតាមសេចក្តីណែនាំលេខ០២០/២៣ចុះថ្ងៃទី ១៥ ខែមីនា ឆ្នាំ២០២៣ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈចំនួន៣០ដុល្លារអាមេរិក ក្រុមហ៊ុននឹងបើកប្រាក់ឧបត្ថម្ភនេះជូនកម្មករ និយោជិត ថ្ងៃទី១៣ខែកក្កដា ឆ្នាំ២០២៣។

អង្គប្រជុំបានបញ្ចប់វេលាម៉ោង ១០និង៣០នាទី នាថ្ងៃខែឆ្នាំដដែលដោយភាគីទាំងសងខាងមានភាពស្និតស្នាល និងការយោគយល់គ្នាក្រោមស្មារតីទទួល និង សហការគ្នាយ៉ាងល្អ។

ភ្នំពេញ.ថ្ងៃទី០៧ខែកក្កដាឆ្នាំ២០២៣

**ស្នាមមេដៃប្រតិភូបុគ្គលិក** **នាយកក្រុមហ៊ុន**

ម៉េត សម្ផស្ស  សៀន សេង  ង៉ែត សុខរ៉ែម  អៀន វ៉ាន់  មៀង ឌី

យ៉ោម លក្ខិណា  ឌុច ឃាន់  សួន ប៊ុណ្ណាត  គួង ណារីម  សំរិត សុម៉ាលី

CamScanner